# របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ យុទ្ធសាស្ត្រភាពចម្រុះផ្នែកវប្បធម៌ និងភាសាឆ្នាំ 2025៖ សេចក្តីសង្ខេប

## អំពីរបាយការណ៍នេះ

នៅថ្ងៃទី 30 ខែមេសា ឆ្នាំ 2024 ទីភ្នាក់ងារជានារ៉ាប់រងជនពិការថ្នាក់ជាតិ (NDIA) បានចេញផ្សាយយុទ្ធសាស្ត្រភាពចម្រុះផ្នែកវប្បធម៌ និងភាសា ឆ្នាំ 2024-2028។

វាបង្ហាញពីវឌ្ឍនភាពនៃលទ្ធផលរយៈពេលខ្លីរបស់យើងនៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពចាប់ពីថ្ងៃទី 30 ខែមេសា ឆ្នាំ 2024 ដល់ថ្ងៃទី 30 ខែមេសា ឆ្នាំ 2025។

របាយការណ៍ពេញលេញមាននៅលើគេហទំព័រ NDIA។

## សម្រាប់យុទ្ធសាស្ត្រ CALD

ភាពចម្រុះផ្នែកវប្បធម៌ និងភាសា (CALD) មានសារៈសំខាន់ខ្លាំងចំពោះសង្គម និងអត្តសញ្ញាណអូស្ត្រាលី។

យើងដឹងថាជនពិការមកពីសហគមន៍ CALD ជួបប្រទះបញ្ហាប្រឈមពិសេសៗ ក្នុងការស្វែងយល់ ទទួលបាន និងប្រើប្រាស់គម្រោងធានារ៉ាប់រងជនពិការថ្នាក់ជាតិ (NDIS)។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពបង្ហាញពីការប្តេជ្ញាចិត្តរបស់យើងក្នុងការធ្វើការជាមួយ ជនពិការមកពីសហគមន៍ CALD។ យើងចង់ជួយពួកគេឱ្យសម្រេចបានលទ្ធផលពី គម្រោងនេះ ឱ្យដូចនឹងជនពិការដទៃទៀតដែរ។

### គោលបំណងនៃយុទ្ធសាស្ត្រ

- ធ្វើឱ្យវាកាន់តែងាយស្រួលសម្រាប់សហគមន៍ CALD ដើម្បីចូលប្រើប្រាស់ និងចូលរួមក្នុង NDIS។

- កែលម្អរបៀបដែលផែនការ NDIS បង្ហាញពីតម្រូវការរបស់អ្នកចូលរួម CALD។
- កែលម្អបទពិសោធន៍ NDIS សម្រាប់អ្នកចូលរួម CALD។

យុទ្ធសាស្ត្រនេះមានវិស័យអាទិភាពចំនួន 6៖

**ហេដ្ឋារចនាសម្ព័ន្ធ**

ការកែលម្អប្រព័ន្ធ និងដំណើរការរបស់យើង ដើម្បីគាំទ្រដល់អ្នកចូលរួម CALD។

**សមត្ថភាពបុគ្គលិក**

បុគ្គលិកដែលមានជំនាញខ្ពស់ដើម្បីឆ្លើយតបកាន់តែប្រសើរឡើង ចំពោះតម្រូវការវប្បធម៌របស់អ្នកចូលរួម។

**ការទំនាក់ទំនងដែលអាចចូលប្រើប្រាស់បាន**

ការចែករំលែកព័ត៌មានតាមរបៀបដែលពេញចិត្តសម្រាប់សហគមន៍ CALD។

**ទីផ្សារ**

ជួយអ្នកផ្តល់សេវា NDIS នៅក្នុងការផ្តល់ជូនសេវាកម្មនានាឱ្យបំពេញទៅតម្រូវការផ្នែកវប្បធម៌របស់អ្នកចូលរួម CALD គ្រួសារ និងអ្នកថែទាំរបស់ពួកគេ។

**ទិន្នន័យ**

ការប្រើប្រាស់ទិន្នន័យកាន់តែប្រសើរឡើង ដើម្បីកែលម្អសេវាកម្មនានាសម្រាប់អ្នកចូលរួម CALD។

**ការផ្សព្វផ្សាយ**

សេវាកម្មនានាដែលតភ្ជាប់ជាមួយ និងអប់រំសហគមន៍ CALD ដែលមិនបានចូលប្រើ NDIS។

# ចំណុចរំលេចសំខាន់ៗនៃឆ្នាំ

## ផែនការនៃការរួមបញ្ចូលគ្នា NDIA CALD ឆ្នាំ 2024-27

នៅខែឧសភា ឆ្នាំ 2024 យើងបានចេញផ្សាយ ផែនការនៃការរួមបញ្ចូលគ្នា NDIA CALD ឆ្នាំ 2024-27។ ការនេះជួយយើងបង្កើតកន្លែងធ្វើការដែលមនុស្ស៖

- មានអារម្មណ៍ថាមានគុណតម្លៃ
- អាចក្លាយជាខ្លួនឯងពិតប្រាកដនៅកន្លែងធ្វើការ។

វាជារបៀបមួយដែលយើងកំពុងកែលម្អសមត្ថភាពបុគ្គលិកដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រ។

ផែនការនៃការបញ្ចូលគ្នាមានសកម្មភាពចំនួន 28 ដែលយើងនឹងអនុវត្តនៅចន្លោះឆ្នាំ 2024 ដល់ឆ្នាំ 2027។ សកម្មភាពទាំងនេះលៃតម្រូវទៅនឹងវិស័យផ្តោតសំខាន់ចំនួន 4៖

- សមត្ថភាពផ្នែកវប្បធម៌ និងភាពជាអ្នកដឹកនាំ
- វប្បធម៌មានការរួមបញ្ចូលគ្នា
- គោលនយោបាយ និងការអនុវត្តដែលមានការរួមបញ្ចូលគ្នា
- ការអភិវឌ្ឍន៍ និងការរីកចម្រើនទៅមុខនៃអាជីព

យើងបានផ្តល់នូវសកម្មភាពសំខាន់ៗមួយចំនួន ហើយបានចាប់ផ្តើមលើអ្វីដែលនៅសេសសល់។

## ក្រុមប្រឹក្សាយោបល់ផ្ទៃក្នុង និងពីខាងក្រៅ CALD

យើងបានបង្កើតក្រុមប្រឹក្សាយោបល់ពីខាងក្រៅមួយ។ នេះធ្វើឱ្យប្រាកដថាយើងស្តាប់ឮ និងទទួលស្គាល់សំឡេងរបស់មនុស្សមានពិការភាពមកពីប្រវត្តិ CALD។

- សមាជិករួមមានមនុស្សមានបទពិសោធន៍ដែលបានឆ្លងកាត់ក្នុងជីវិត ឬដឹងពីតម្រូវការរបស់មនុស្សមានពិការភាពមកពីប្រវត្តិ CALD។
- ក្រុមនេះជួបគ្នាពីរដងក្នុងមួយខែ។

យើងក៏បានបង្កើតក្រុមប្រឹក្សាយោបល់ផ្ទៃក្នុង CALD ផងដែរ។ ការបង្កើតនេះផ្តល់ជូនជំនួយ និងការឧបត្ថម្ភដើម្បីអនុវត្តសកម្មភាពនានានៃយុទ្ធសាស្ត្រនេះ។

សមាជិកទាំងនេះ រួមមាន៖

- NDIA CALD ជើងឯក
- បុគ្គលិកសេវាប្រតិបត្តិជាន់ខ្ពស់
- នាយកដែលរចនា និងផ្តល់ការកែទម្រង់គម្រោង

## សកម្មភាពការចូលរួមសហគមន៍

ក្នុងរយៈពេល 12 ខែដល់ថ្ងៃទី 30 ខែមេសា ឆ្នាំ 2025 យើងបានប្រារព្ធធ្វើសកម្មភាពចំនួន 192 ជាមួយអង្គការសហគមន៍ និងសេវាកម្មសំខាន់ៗ។
យើងបានទំនាក់ទំនងជាមួយអ្នកចូលរួមពាក់ព័ន្ធប្រហែល 2,200 នាក់។

សកម្មភាពនានាបានធ្វើឱ្យប្រសើរឡើងនូវព័ត៌មានដែលសហគមន៍ CALD មានអំពី NDIS។ គោលដៅគឺដើម្បីជួយមនុស្សដែលមានពិការភាពមកពីប្រវត្តិ CALD៖

- ចូលប្រើប្រាស់ NDIS។
- ប្រើការគាំទ្រមនុស្សមានពិការភាព។

ក្នុងឧទាហរណ៍មួយ យើងបានធ្វើការជាមួយបណ្ដាញសុខភាពជនភៀសខ្លួននៃប្រទេសអូស្ត្រាលី។ យើងបានរៀបចំវគ្គមួយចំនួនដើម្បីជួយមនុស្សឱ្យយល់ដឹងពីដំណើរការ NDIS និងរបៀបដែលពួកគេធ្វើការជាមួយប្រព័ន្ធសុខភាព។

វគ្គទាំងនេះក៏បានជួយអ្នកជំនាញផ្នែកសុខភាពផងដែរ៖

- បង្ហាញមនុស្សពីរបៀបចូលប្រើប្រាស់ NDIS
- ធ្វើឱ្យប្រាកដថាពួកគេផ្ដល់ព័ត៌មាន និងការគាំទ្រផ្នែកវប្បធម៌សមរម្យដល់មនុស្សដែលមានពិការភាពមកពីប្រវត្តិ CALD។

# ការអនុវត្តយុទ្ធសាស្ត្រ

## កំណែទម្រង់ NDIS

នៅខែតុលា ឆ្នាំ 2024 ច្បាប់ NDIS ថ្មី *(ច្បាប់ស្តីពីវិសោធនកម្មគម្រោងធានារ៉ាប់រងជនពិការថ្នាក់ជាតិ [ធ្វើឱ្យ NDIS ត្រឡប់ទៅគន្លងត្រូវវិញ លេខ 1])* បានចូលជាធរមាន។ នេះគឺបន្ទាប់ពីទីភ្នាក់ងារបានបោះពុម្ពផ្សាយយុទ្ធសាស្ត្រ និងផែនការសកម្មភាព CALD។

ច្បាប់ថ្មីមានន័យថា កំណែទម្រង់ NDIS ដ៏ធំក្នុងរយៈពេល 5 ឆ្នាំខាងមុខ។ ការរចនារួមគ្នា និងការផ្សព្វផ្សាយកំណែទម្រង់ទាំងនេះ គឺជាអាទិភាពរបស់យើងនៅក្នុងពេលនេះ។

កំណែទម្រង់បង្កើតបញ្ហាប្រឈមមួយចំនួនជាមួយយុទ្ធសាស្ត្រ CALD។ ប៉ុន្តែកំណែទម្រង់ទាំងនោះក៏ជាឱកាសមួយដើម្បីរួមបញ្ចូលតម្រូវការរបស់អ្នកចូលរួម CALD ពីរបៀបដែលយើងរចនា NDIS ដើម្បីធ្វើការនាពេលអនាគត។

## អ្វីខ្លះដែលយើងកំពុងធ្វើ

- យើងចង់ឱ្យកំណែទម្រង់ទាំងនោះពិចារណាលើតម្រូវការរបស់អ្នកចូលរួម និងមនុស្សដែលមានពិការភាពមកពីសហគមន៍ CALD។
- យើងនឹងរចនា និងប្រើប្រាស់ការផ្លាស់ប្តូរនានា ដើម្បីឱ្យវាស៊ីសង្វាក់ជាមួយនឹងចក្ខុវិស័យយុទ្ធសាស្រ្ត CALD។
- យើងកំពុងពិនិត្យសើរើលើរបៀបដែលយើងអនុវត្តសកម្មភាពនានានៃយុទ្ធសាស្ត្រនេះ។
- យើងអាចកែលម្អសកម្មភាពមួយចំនួនពីបទពិសោធន៍របស់យើងអំពីយុទ្ធសាស្ត្រ និងផែនការសកម្មភាព CALD ក្នុងរយៈពេល 12 ខែកន្លងមកនេះ។
- យើងនឹងធ្វើការជាមួយក្រុមប្រឹក្សាយោបល់ផ្ទៃក្នុង និងពីខាងក្រៅ សម្រាប់ការពិនិត្យសើរើរឿងនេះ។
- យើងនឹងចែករំលែកលទ្ធផល។

## ធ្វើការនៅទូទាំងរដ្ឋាភិបាល

សម្រាប់សកម្មភាពមួយចំនួន យើងបានធ្វើការជាមួយក្រសួង និងទីភ្នាក់ងាររដ្ឋាភិបាលមួយចំនួន រួមមានៈ

- គណៈកម្មការត្រួតពិនិត្យគុណភាព និងសុវត្ថិភាព NDIS (គណៈកម្មការ NDIS)
- ក្រសួងសេវាកម្មសង្គម
- ក្រសួងមហាផ្ទៃ។

ផែនការការងារ និងធនធានផ្សេងៗគ្នារបស់ពួកគេ មានន័យថាសកម្មភាពមួយចំនួន បានចាប់ផ្តើមយឺតជាងនៅក្នុងផែនការសកម្មភាព។

យើងបានជួបជាមួយ Services Australia ដើម្បីស្វែងយល់ពីបទពិសោធន៍របស់ពួកគេ ក្នុងការធ្វើការជាមួយសហគមន៍ CALD និងនៅទូទាំងរដ្ឋាភិបាល។

យើងនឹងបន្តធ្វើការជាមួយផ្នែករដ្ឋាភិបាលផ្សេងទៀត ដើម្បីស្វែងរកវិធីដើម្បីធ្វើឱ្យមានវឌ្ឍនភាពលើសកម្មភាពនានា។

## កង្វះកម្លាំងពលកម្ម និងទីផ្សារ

យើងបានឃើញពីតម្រូវការដើម្បីដោះស្រាយកង្វះខាតអ្នកបកប្រែផ្ទាល់មាត់ដែលត្រូវទទួលស្គាល់ទូទាំងប្រទេសសម្រាប់ភាសាជាច្រើនរួមទាំង Auslan ផងដែរ។ យើងដឹងថា រឿងនេះបង្កើតឧបសគ្គដល់ការចូលប្រើប្រាស់ NDIS និងការប្រើប្រាស់ផែនការ NDIS នានា។

NDIA មានមធ្យោបាយកំណត់ដើម្បីមានឥទ្ធិពលលើទំហំនៃកម្លាំងការងារនេះ។ ប៉ុន្តែយើងនឹងបន្តមើលពីរបៀបដែលយើងអាចជួយកម្លាំងការងារអ្នកបកប្រែផ្ទាល់មាត់ បច្ចុប្បន្នឱ្យយល់អំពី NDIS។

# សេចក្តីសង្ខេបនៃវឌ្ឍនភាព

របាយការណ៍ប្រចាំឆ្នាំបង្ហាញពីវឌ្ឍនភាពនៃលទ្ធផលរយៈពេលខ្លីនៅក្នុងយុទ្ធសាស្រ្ត និងផែនការសកម្មភាពរបស់ CALD នៅថ្ងៃទី 30 ខែមេសា ឆ្នាំ 2025។ ទាំងនេះគឺជាគោលដៅដែលយើងចង់សម្រេចបាននៅក្នុងរយៈពេល 2 ឆ្នាំដំបូងនៃយុទ្ធសាស្រ្ត។

ក្នុងចំណោមលទ្ធផលទាំងនេះពីសកម្មភាពចំនួន 28 នៅក្នុងផែនការសកម្មភាព CALD៖

- យើងបានបញ្ចប់ 1។
- យើងបានចាប់ផ្តើម 15។
- យើងមិនទាន់បានចាប់ផ្តើម 12។

យើងមានស្ថានភាពព័ត៌មានថ្មីៗសម្រាប់រាល់សកម្មភាពនៅក្នុងរបាយការណ៍ពេញលេញនៅលើគេហទំព័រ។

សូមចូលមើល www.ndis.gov.au/strategies/cultural-and-linguistic-diversity-strategy សម្រាប់ព័ត៌មានបន្ថែមអំពី៖

- យុទ្ធសាស្រ្ត CALD ឆ្នាំ 2024-2028
- ផែនការសកម្មភាពយុទ្ធសាស្រ្ត CALD
- របាយការណ៍ប្រចាំឆ្នាំ យុទ្ធសាស្រ្ត CALD ឆ្នាំ 2025